Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

36842

# ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក ៖ សៀវភៅមគ្គុទេសក៍សំរាប់អាជីវកម្ម



IFC
International Finance Corporation
World Bank Group

MPDF
MEKONG PRIVATE SECTOR DEVELOPMENT FACILITY

# មាតិកា

**ពាក្យគ្រាត់** ........ v
**បុព្វកថា** ........ ix
**សេចក្តីថ្លែងអំណរគុណ** ........ xi
**ជំពូកទី ១** សាវតារពាក់ព័ន្ធ ........ ១
**ជំពូកទី ២** ខ្លឹមសារសង្ខេបតាមវិស័យ ........ ៧
កសិអាជីវកម្មទូទៅ ........ ៧
អង្ករ ........ ៨
គ្រាប់ស្វាយចន្ទី ........ ៨
បសុសត្វ ........ ៩
ផ្លែស្វាយ ........ ៩
ប្រេងរុក្ខជាតិ ........ ១០
ស្រាទឹកត្នោត ........ ១០
កៅស៊ូ ........ ១១
ត្រី ........ ១១
ផលិតផលសូត្រ ........ ១១
សង្ហារិមដែលធ្វើអំពីឫស្សី និង ផ្តៅ ........ ១២
សំលៀកបំពាក់ ........ ១២
សេវាហិរញ្ញវត្ថុ ........ ១៣
សេវាសំណង់ និង សេវាពាក់ព័ន្ធ ........ ១៤
**ជំពូកទី ៣** កិច្ចសន្យារបស់ WTO ........ ១៥
**ជំពូកទី ៤** ប្រភពដើម និង គោលការណ៍របស់ WTO ........ ២១

ជំពូកទី ៥ បរិយាកាសបទបញ្ញត្តិថ្មីចំពោះអាជីវកម្មក្នុងស្រុក ....................................................................៣៣
ជំពូកទី ៦ បរិយាកាសវិនិយោគថ្មី ....................................................................................................៤៣
ជំពូកទី ៧ បរិយាកាសថ្មីក្នុងការធ្វើពាណិជ្ជកម្ម : ការបើកទីផ្សារ ......................................................៥៣
ជំពូកទី ៨ បរិយាកាសធ្វើពាណិជ្ជកម្មថ្មី : ដំណោះស្រាយជាមួយនឹងរបាំងមិនមែនពន្ធគយ ..........................៦៣
ជំពូកទី ៩ ការក្លាយទៅជាមានភាពប្រកួតប្រជែង និង ដំណោះស្រាយជាមួយនឹងការប្រកួតប្រជែង .....................៦៩

ឧបសម្ព័ន្ធ ក១ អាជីវកម្មកសិកម្ម : ទូទៅ ........................................................................................៧៧
ឧបសម្ព័ន្ធ ក២ អាជីវកម្មកសិកម្ម : អង្ករ .........................................................................................៨៩
ឧបសម្ព័ន្ធ ក ៣ អាជីវកម្មកសិកម្ម : គ្រាប់ស្វាយចន្ទី .......................................................................១០១
ឧបសម្ព័ន្ធ ក៤ អាជីវកម្មកសិកម្ម : បសុសត្វ ..................................................................................១០៩
ឧបសម្ព័ន្ធ ក៥ អាជីវកម្មកសិកម្ម : ផ្លែស្វាយ ....................................................................................១១៥
ឧបសម្ព័ន្ធ ក៦ អាជីវកម្មកសិកម្ម : ប្រេងរុក្ខជាតិ ...........................................................................១២៣
ឧបសម្ព័ន្ធ ក៧ អាជីវកម្មកសិកម្ម : ស្រាទឹកត្នោត.............................................................................១២៩
ឧបសម្ព័ន្ធ ក៨ អាជីវកម្មកសិកម្ម : កៅស៊ូ.......................................................................................១៣៣
ឧបសម្ព័ន្ធ ខ ត្រី ..........................................................................................................................១៣៩
ឧបសម្ព័ន្ធ គ១ សិប្បកម្ម: ផលិតផលសូត្រ ......................................................................................១៤៧
ឧបសម្ព័ន្ធ គ២ សិប្បកម្ម : សង្ហារឹមធ្វើអំពីឬស្សី និង ផ្តៅ ..................................................................១៥៣
ឧបសម្ព័ន្ធ ឃ សម្លៀកបំពាក់ .........................................................................................................១៥៩
ឧបសម្ព័ន្ធ ង១ សេវាហិរញ្ញវត្ថុ ........................................................................................................១៦៩
ឧបសម្ព័ន្ធ ង២ សេវាសំណង់ និង សេវាពាក់ព័ន្ធ ...........................................................................១៧៥
ឧបសម្ព័ន្ធ ច បទពិសោធរបស់សមាជិកមួយទៀតរបស់ WTO : ប្រទេសអ៊ូហ្គង់ដា ...................................១៧៩

ឧបសម្ព័ន្ធ ទី ១ ធនធានពត៌មាន ..................................................................................................១៩១
ឧបសម្ព័ន្ធ ទី ២ ការគាំទ្រការងារជំរុញពាណិជ្ជកម្មនៅកម្ពុជា ...........................................................១៩៥
ឧបសម្ព័ន្ធ ទី ៣ មុខងាររបស់កាំកុងត្រូល .....................................................................................១៩៩
ឧបសម្ព័ន្ធ ទី ៤ អាស័យដ្ឋានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ............................................២០១
ឧបសម្ព័ន្ធ ទី ៥ សន្ទានុក្រមនៃបច្ចេកស័ព្ទ WTO ..........................................................................២០៣

# ពាក្យកាត់

| | |
|---|---|
| AFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន |
| AGOA | ច្បាប់ស្តីពីកំណើននិងកាលានុវត្តភាពរបស់ទ្វីបអាហ្វ្រិក |
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| ATC | កិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌនិងសំលៀកបំពាក់ |
| BSE | ជំងឺគោឆ្កួត |
| Camcontrol | នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញអាហារ័ណ នីហ័រណ និងបង្រ្កាបការក្លែងបន្លំ (នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម) |
| CAP | គោលនយោបាយកសិកម្មទូទៅ |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល ស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៏កម្ពុជា |
| CEPT | ពន្ធគយអនុគ្រោះដែលមានប្រសិទ្ធភាពទូទៅ |
| c.i.f. | ថ្លៃធានារ៉ាប់រង និងថ្លៃដឹកជញ្ជូន |
| C/O | វិញ្ញាបនបត្រប្រភពដើម |
| COMESA | ផ្សាររួមនៃអាហ្វ្រិកខាងកើតនិងខាងត្បូង |
| EAC | សហគមន៏អាហ្វ្រិកខាងកើត |
| EBA | អ្វី១ទាំងអស់លើកលែងតែអាវុធ |
| EU | សហភាពអឺរ៉ុប |
| FAOSTAT | ទិន្នន័យមូលដ្ឋានផ្នែកស្ថិតិរបស់អង្គការសហប្រជាជាតិស្តីពីស្បៀងអាហារនិងការចាត់តាំងផ្នែកកសិកម្ម |
| FDI | វិនិយោគផ្ទាល់ពីបរទេស |
| f.o.b. | ថ្លៃផ្ទុកលើនាវានិងថ្លៃប្រគល់នៅកំពង់ផែ |
| GATT | កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម |
| GATS | កិច្ចព្រមព្រៀងទូទៅស្តីពីការធ្វើពាណិជ្ជកម្មសេវាកម្ម |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GNP | ផលិតផលជាតិសរុប |
| ILO | អង្គការពលកម្មអន្តរជាតិ |

| | |
|---|---|
| INBAR | បណ្ដាញឬស្សី និងផ្ដៅអន្តរជាតិ |
| IP | កម្មសិទ្ធិបញ្ញា |
| IPR | សិទ្ធិស្ដីពីកម្មសិទ្ធិបញ្ញា |
| ITRO | អង្គការក្រៅស្ទូត្រីភាគីអន្តរជាតិ |
| LDC | ប្រទេសដែលមានការអភិវឌ្ឍតិចបំផុត |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| MFA | កិច្ចព្រមព្រៀងសរសៃអំបោះ |
| MFN | ប្រជាជាតិដែលបានទទួលការអនុគ្រោះបំផុត |
| MoC | ក្រសួងពាណិជ្ជកម្ម |
| NAFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅអាមេរិកខាងជើង |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| OPEC | អង្គការនៃបណ្ដាប្រទេសនាំប្រេងចេញ |
| PSI | អធិការកិច្ចមុនពេលផ្ទុក |
| SGS | ក្រុមហ៊ុនត្រួតពិនិត្យទូទៅ |
| SME | សហគ្រាសធុនតូចនិងធុនមធ្យម |
| SPS | អនាម័យនិងភូតគាមអនាម័យ |
| TBT | ឧបសគ្គផ្នែកបច្ចេកទេសចំពោះពាណិជ្ជកម្ម |
| TRIMs | វិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម |
| TRIPS | ទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃសិទ្ធិស្ដីពីកម្មសិទ្ធិបញ្ញា |
| UK | ចក្រភពអង់គ្លេស |
| UN | អង្គការសហប្រជាជាតិ |
| UN Comtrade | ទិន្នន័យមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្ដីពីពាណិជ្ជកម្ម |
| UNBS | ការិយាល័យស្តង់ដាររបស់ប្រទេសអ៊ូហ្គង់ដា |
| UNCTAD | សន្និសីទអង្គការសហប្រជាជាតិស្ដីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ |
| UNEP | កម្មវិធីរបស់អង្គការសហប្រជាជាតិស្ដីពីបរិស្ថាន |
| US | សហរដ្ឋអាមេរិក |
| USDA | ក្រសួងកសិកម្មរបស់សហរដ្ឋអាមេរិក |
| VAT | អាករលើតម្លៃបន្ថែម |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# បុព្វកថា

ទោះបីជាយើងចូលចិត្ត ឬមិនចូលចិត្តក៏ដោយ សាកលភាវូបនីយកម្មគឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង។ ជាលទ្ធផលនៃការរីកចំរើនខាងមធ្យោបាយដឹកជញ្ជូន និងគមនាគមន៍ព្រមទាំងការបើកទូលាយនៃសេដ្ឋកិច្ចនានានៅលើពិភពលោក ឥឡូវនេះប្រទេសទាំងឡាយកាន់តែមានទំនាក់ទំនងជាមួយគ្នាឡើង។ ដោយទទួលស្គាល់តថភាពនេះ ទើបប្រទេសកម្ពុជាសម្រេចចិត្តចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ទោះបីជា ដំណើរការនៃការចូលជាសមាជិកនេះគឺជាការពិបាកមួយ ហើយកម្ពុជាត្រូវទទួលយកល័ក្ខខ័ណ្ឌដែលលើសហួសពី បទដ្ឋានសម្រាប់ប្រទេសដែលមិនសូវអភិវឌ្ឍន៍ក៏ដោយ ក៏យើងសុខចិត្តទទួលយកដែរ។ យើងមានហេតុផលច្បាស់លាស់ក្នុងការធ្វើដូច្នោះ។ ប្រទេសយើងមានកម្លាំងពលកម្មដែលកើនឡើងយ៉ាងលឿន ប៉ុន្តែយើងគ្មានការងារគ្រប់គ្រាន់សំរាប់ពួកគេទេ។ ហើយនៅពេលជាមួយគ្នានេះយើងត្រូវប្រឈមមុខជាមួយនឹងការប្រកួតប្រជែងខាងសេដ្ឋកិច្ចយ៉ាងខ្លាំងពីសំណាក់ប្រទេសជិតខាងរបស់យើង។ មានតែ វិស័យឯកជនដែលរីកចំរើនមួយទេទើបអាចជួយបង្កើតការងារដែលមាននិរន្តភាពបាន។

ចំពោះប្រទេសដែលមានទំហំតូច និងមានកំរិតអភិវឌ្ឍន៍ដូចប្រទេសកម្ពុជា គន្លឹះសំខាន់មួយសំរាប់ធ្វើឱ្យវិស័យឯកជនរីកចំរើនបាន គឺពាណិជ្ជកម្មអន្តរជាតិ។ ដូចដែលបទពិសោធន៍នៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៃប្រទេសមួយចំនួនបានបង្ហាញក្នុងរយៈពេលពីរទសវត្សកន្លងមកនេះ ប្រទេសដែលមានផលធៀបពាណិជ្ជកម្មលើ ផលិតផលក្នុងស្រុកសរុប (GDP) ខ្ពស់ជាងគេមានការរីកចំរើនខាងសេដ្ឋកិច្ចជាមធ្យម ៣,៥ % ក្នុងមួយឆ្នាំ នៅក្នុងកំឡុងទសវត្ស១៩៨០ និង ៥%ក្នុងមួយឆ្នាំ នៅក្នុងកំឡុងទសវត្ស១៩៩០។ នៅក្នុងកំឡុងពេលនេះដែរ ប្រទេសដែលមិនបានធ្វើសមាហរណកម្ម សេដ្ឋកិច្ច មានការរីកចំរើនជាមធ្យម ត្រឹមតែ ០,៨%ក្នុងមួយឆ្នាំនៅទសវត្ស១៩៨០ និង ១,៥ % នៅទសវត្ស ១៩៩០។

ប៉ុន្តែ ដើម្បីធ្វើឱ្យពាណិជ្ជកម្មមានអត្ថប្រយោជន៍ចំពោះគ្នាទៅវិញទៅមក គេត្រូវមានគោលការណ៍រួមមួយចំនួនសំរាប់គ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម។ គោលការណ៍ទាំងនេះរួមមាន ភាពបើកចំហ តម្លាភាព ភាពដែលអាចប្រមើលទុកមុន ការមិនរើសអើង និងប្រព័ន្ធដោះស្រាយជម្លោះដោយផ្អែកលើបទបញ្ញត្តិ។ ដោយចូលជាសមាជិករបស់ WTO យើងមិនត្រឹមតែបង្កើនលទ្ធភាពក្នុងការពង្រីកទីផ្សារ និងបានទទួលការគោរពត្រឹមត្រូវពីប្រទេសដៃគូពាណិជ្ជកម្ម ដែលមានឥទ្ធិពលនៅក្នុងពិភពលោកប៉ុណ្ណោះទេ វាថែមទាំងផ្តល់ជាសញ្ញាច្បាស់លាស់មួយ ដល់សក្តានុពលវិនិយោគិនថា ប្រទេសកម្ពុជាគឺជាទីកន្លែងល្អ សំរាប់ប្រកបរបរពាណិជ្ជកម្ម។

ប៉ុន្តែសមាជិកភាពនៅក្នុង WTO និងការធ្វើកំណែទំរង់រដ្ឋាភិបាលដែលចាំបាច់មួយចំនួន មិនទាន់គ្រប់គ្រាន់ទេ សំរាប់ ទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្ម ។ ប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍ពីសមាជិកភាពនៃ WTO ប្រសិនបើក្រុមហ៊ុនអាជីវកម្មទាំងឡាយយល់ដឹងពីវិធាន និងបទបញ្ញត្តិនៃបរិយាកាសពាណិជ្ជកម្មថ្មីៗ ដើម្បីឱ្យគេ ទាញយកផលប្រយោជន៍ពីឱកាសថ្មីៗ និងទប់ទល់ជាមួយនឹងឧបសគ្គចំពោះមុខ ។

ហេតុនេះហើយទើបយើងសហការជាមួយ កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) របស់សាជីវកម្ម ហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងការរៀបចំតាក់តែងសៀវភៅមគ្គុទេសនេះ និងគំនិតផ្តួចផ្តើមផ្សេងៗទៀត ដើម្បីពន្យល់ ដល់វិស័យឯកជនពីអង្គការ WTO ។ ដូចដែលអស់លោក លោកស្រី នឹងឃើញនៅពេលអានសៀវភៅមគ្គុទេសនេះ សៀវភៅនេះចែកចេញជាពីរផ្នែកធំៗ ។ ផ្នែកទីមួយរៀបរាប់ពីវិធាននិងបទបញ្ញត្តិរួម ។ ឯផ្នែកទីពីរ ពិនិត្យពីលទ្ធភាព នៃឥទ្ធិពលរបស់សមាជិកភាព WTO មកលើវិស័យសេដ្ឋកិច្ចមួយចំនួន ។ ផ្នែកនេះសំខាន់ណាស់ ព្រោះវាផ្តល់ពត៌មានពីទិដ្ឋភាពទូទៅនៃទីផ្សារនិមួយៗ និងភាពលំបាកដែលអាជីវកម្មកម្ពុជានឹងជួបប្រទះ ព្រមទាំងប្រភពពត៌មានផ្សេងទៀតសំរាប់ទីផ្សារនិមួយៗ ។

ក្រសួងពាណិជ្ជកម្មសូមថ្លែងអំណរគុណដល់ MPDF ដែលបានសហការជាមួយយើងក្នុងការផលិតសៀវភៅ មគ្គុទេសនេះ ។ យើងសង្ឃឹមថា សៀវភៅមគ្គុទេសនេះនឹងក្លាយទៅជាប្រភពដ៏មានសារប្រយោជន៏មួយសំរាប់សហគ្រិនរបស់យើងដែលចង់ទាញយកប្រយោជន៏ពីសមាជិកភាពរបស់កម្ពុជានៅក្នុង WTO ។



**ចម ប្រសិទ្ធ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ខែមិនា ឆ្នាំ ២០០៥

# សេចក្តីថ្លែងអំណរគុណ

**ប្រទេសកម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក** (WTO)**: សៀវភៅមគ្គុទេសសំរាប់ អាជីវកម្ម** នេះ ត្រូវបានផលិតឡើងរួមគ្នា ដោយក្រសួងពាណិជ្ជកម្ម និងកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ ទន្លេមេគង្គ (MPDF) ។ ឯកឧត្តម **សុខ ស៊ីផាន់ណា** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម និង លោក Adam Sack នៃ MPDF បានផ្តល់ការណែនាំ និងគាំទ្រដល់ការបង្កើតសៀវភៅនេះឡើង ។

លោក **ហោ សុនាថ** ជាអ្នកទទួលខុសត្រូវក្នុងការបង្កើតឯកសារណែនាំនេះ ក្រោមការដឹកនាំរបស់ អ្នកស្រី Trang Nguyen ។ លោក David Woods នាយកគ្រប់គ្រងរបស់ក្រុមហ៊ុន World Trade Agenda Consultants ជាអ្នកនិពន្ធឯកសារនេះ ។ លោក **តឹករ៉េត សំរេច** និង លោក **យូ ម៉ាប់** បានចូលរួមក្នុងការស្រាវជ្រាវ និងពិនិត្យមើលឯកសារនេះ ។

អ្នកស្រី Jennifer Herink និងអ្នកស្រី Ann Bishop ជាអ្នកកែសំរួល និងពិនិត្យមើលឡើងវិញ នូវឯកសារច្បាប់ដើម ។ កញ្ញា **យូ សូនទី** បានចូលរួមផ្តល់យោបល់លើឯកសារព្រៀង និងជួយក្នុងការបកប្រែ ។ លោក **ទា សារ៉ូវ៉ា** ជាអ្នកបកប្រែឯកសារនេះ ហើយ អ្នកស្រី **ទា សាន** ជាអ្នកពិនិត្យមើលការបកប្រែ ទទួលខុសត្រូវលើការផលិត និង ជួយខាងផ្នែករដ្ឋាបាល ។ អ្នកស្រី **គា គន្ធា** ទទួលខុសត្រូវលើផ្នែករចនាអក្សរ និងរូបភាព ។ អ្នកស្រី Nguyen Thi My ក៏បានជួយសំរួលខាងផ្នែករដ្ឋាបាលផងដែរ ។

# ជំពូកទី ១

# សាវតារពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជាបានក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៤។ កម្ពុជាបានចរចាអំពីល័ក្ខខ័ណ្ឌនៃការចូល WTO ជាមួយសមាជិកដទៃទៀត អស់រយៈពេលជិត ៩ ឆ្នាំ។ គេបានទទួលស្គាល់សមាជិកភាពកម្ពុជា ជាផ្លូវការ នៅខែកញ្ញា ឆ្នាំ ២០០៣ នាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី WTO នៅទីក្រុងកានគុននៃប្រទេសម៉ិចស៊ិក។ ការចូលជាសមាជិក WTO របស់កម្ពុជានេះ បានទទួលសច្ចាប័នពីរដ្ឋសភា និងបានទទួលការអនុម័តយល់ព្រមពីព្រឹទ្ធសភា នៅខែកញ្ញា ឆ្នាំ ២០០៤។

តាមរយៈការចូល WTO ប្រទេសកម្ពុជាទទួលបាននូវទំនាក់ទំនងបែបកិច្ចសន្យា ដែលអាចអនុវត្តបានជាមួយស្ទើរតែគ្រប់ប្រទេសទាំងអស់ ដែលមានតួនាទីសំខាន់ៗ នៅក្នុងវិស័យពាណិជ្ជកម្ម។ កិច្ចសន្យា WTO គឺជាកញ្ចប់នៃការសន្យា និងវិធាន ដែលបើកឱ្យមានច្រកចូលទៅកាន់ទីផ្សារទាំងឡាយបាន។ គេអនុវត្តកិច្ចសន្យានេះតាមរយៈប្រព័ន្ធដោះស្រាយវិវាទ ដែលមានសមត្ថកិច្ចដ៏ធំលើផ្នែកច្បាប់ និងពាណិជ្ជកម្ម។

ប្រព័ន្ធច្បាប់របស់ WTO មានលក្ខណៈស្មុគស្មាញខ្លាំងណាស់។ ប្រព័ន្ធនេះមានកិច្ចព្រមព្រៀងប្រមាណ ២០ រួមជាមួយនឹងសេចក្តីសម្រេចចិត្ត និងអនុស្សារណៈនានា ជាបន្ថែមទៀត។ ប៉ុន្តែគោលការណ៍នៃប្រព័ន្ធនេះមានលក្ខណៈសាមញ្ញណាស់។ គោលការណ៍ទាំងនេះរួមមានៈ ការមិនរើសអើងចំពោះសមាជិក តម្លាភាពនៃច្បាប់ និងវិធានពាណិជ្ជកម្ម ការយកចិត្តទុកដាក់ជាពិសេស ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍ ការប្រើប្រាស់ពន្ធគយគឺសម្រាប់តែការពារទីផ្សារ និងការធ្វើសេរីភាវូបនីយកម្មទីផ្សារជាជំហានៗ។ គណៈកម្មាធិការ និងក្រុមប្រឹក្សានានា រួមមានអ្នកតំណាងរបស់សមាជិក WTO ដែលពិនិត្យមើលរាល់កិច្ចព្រមព្រៀងទាំងអស់ និងមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស។

**ឥទ្ធិពលនៃសមាជិកភាព WTO មកលើវិស័យឯកជនកម្ពុជា**

ប្រការសំខាន់គឺ គេគប្បីចងចាំថា ក្នុងរយៈពេលខ្លីបន្ទាប់ពីកម្ពុជាបានចូលជាសមាជិក WTO គេនឹងពុំឃើញមានផលប្រយោជន៍ ឬបញ្ហាត្រូវប្រឈមមុខឡើយ។ តាមពិតមានការផ្លាស់ប្តូរមួយចំនួនបានកើតឡើង ក្នុងអំឡុងពេលនៃដំណើរការចូល WTO រីឯការផ្លាស់ប្តូរដទៃទៀតនឹងកើតមាននៅក្នុងបណ្តាឆ្នាំខាងមុខ។

សមាជិកភាពក្នុង WTO មិនធានាជោគជ័យនៅក្នុងពាណិជ្ជកម្មពិភពលោកឡើយ។ ផ្ទុយទៅវិញ WTO ផ្តល់នូវក្របខ័ណ្ឌមួយ សម្រាប់កែទម្រង់សេដ្ឋកិច្ច និងកំណែទម្រង់ដទៃទៀត ដែលនឹងជួយប្រទេសកម្ពុជា ឱ្យមានលទ្ធភាពប្រកួតប្រជែងនៅក្នុងទីផ្សារបរទេស ហើយទន្ទឹមពេលជាមួយគ្នានេះ សមាជិកភាពនេះក៏ផ្តល់បរិយាកាសដែលទាក់ទាញការវិនិយោគផងដែរ។ មួយរយៈកាលក្រោយមក នឹងមានឱកាសទីផ្សារថ្មីៗ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពប្រកួតប្រជែង និងសហគ្រិនភាពខ្ពស់។ ក៏ប៉ុន្តែ ជោគជ័យនៃការនាំចេញនឹងកើតឡើងបាន លុះត្រាតែមានសម្ព័ន្ធភាពប្រកបដោយផ្លែផ្កា រវាងរដ្ឋាភិបាល និងផ្នែកឯកជន។ ក្រុមហ៊ុននៅកម្ពុជា ចាំបាច់ត្រូវកំណត់អត្តសញ្ញាណនៃផលប្រយោជន៏របស់ខ្លួន នៅក្នុងប្រព័ន្ធពាណិជ្ជកម្ម WTO ហើយធ្វើយ៉ាងណា ឱ្យរដ្ឋាភិបាលការពារផលប្រយោជន៏ទាំងនោះ បានគ្រប់គ្រាន់នៅទីក្រុងហ្សឺណែវ។

ឥទ្ធិពលរបស់ WTO នឹងកើតឡើងជាបួនកម្រិត។ ទី ១: ក្នុងរយៈពេលខ្លីបង្គួរ ឥទ្ធិពលនោះគឺការអនុវត្តការសន្យាកែទម្រង់ក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលក្នុងប្រទេស។ ទាំងនេះគឺជាល័ក្ខខ័ណ្ឌ ដែលគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម និងពាណិជ្ជកម្ម នៅក្នុងប្រទេសកម្ពុជា។ ទី ២: ប្រសិនបើមានការកែលំអហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងវិធានពាណិជ្ជកម្ម នោះសមាជិកភាពក្នុង WTO អាចនឹងទាក់ទាញការវិនិយោគទាំងឡាយបាន។ ទី ៣: ប្រសិនបើក្រុមហ៊ុនកម្ពុជាមានផលិតភាពខ្ពស់ និងមានលទ្ធភាពផ្គត់ផ្គង់ផលិតផលដែលមានគុណភាពល្អ បានទាន់ពេលវេលាក្នុងតម្លៃប្រកបដោយលក្ខណៈប្រកួតប្រជែង នោះល័ក្ខខ័ណ្ឌចូលទៅកាន់ទីផ្សារ ដែលមានកំណត់នៅក្នុង WTO និងកំណត់ដោយកិច្ចព្រមព្រៀងប្រចាំតំបន់ ព្រមទាំងកិច្ចព្រមព្រៀងដែលមានលក្ខណៈអនុគ្រោះដទៃទៀត នឹងក្លាយទៅជាកត្តានាំឱ្យសម្រេចជោគជ័យ សំរាប់ផ្នែកឯកជនកម្ពុជា។ ទី ៤: WTO ផ្តល់នូវឱកាសមួយចំនួន ពោលគឺពុំមែនគ្រាន់តែធ្វើឱ្យសមាជិករបស់ខ្លួនកាន់តែមានលក្ខណៈប្រកួតប្រជែងប៉ុណ្ណោះទេ តែថែមទាំងជួយ ដល់ពួកគេឱ្យចេះទប់ទល់ជាមួយនឹងការប្រកួតប្រជែងនៅក្នុងទីផ្សាររបស់ខ្លួនផ្ទាល់ផងដែរ។

ល័ក្ខខ័ណ្ឌនៃការចូល WTO រួមមានការសន្យារបស់ប្រទេសកម្ពុជា ក្នុងការបោះជំហានទៅមុខ ជាមួយនឹងកម្មវិធីកំណែទម្រង់ច្បាប់ រាប់ទាំងការបង្កើតតុលាការពាណិជ្ជកម្មរបស់កម្ពុជាផងដែរ។ បរិយាកាសច្បាប់នឹងរងឥទ្ធិពលផ្ទាល់ពីកិច្ចព្រមព្រៀងផ្សេងៗរបស់ WTO។ ឧទាហរណ៍ វិធានកំណត់តម្លៃទំនិញសម្រាប់គិតពន្ធនាំចូល និងអាករលើតម្លៃបន្ថែម (VAT) របស់នាយកដ្ឋានគយ នឹងធ្វើឱ្យក្រុមហ៊ុន និងអ្នកនាំចូលអាចប្រមាណដឹងជាមុននូវតម្លៃពន្ធដារ និងពន្ធគយ។ ដូចគ្នាដែរ កិច្ចព្រមព្រៀងរបស់ WTO ស្តីអំពីអធិការកិច្ចមុនពេលបញ្ជូន ទំនិញ (PSI) និងការផ្តល់អាជ្ញាបណ្ណនាំចូល នឹងលុបបំបាត់កង្វល់អំពីចំណាត់ការ ចំពោះទំនិញនៅកំពង់ផែនានា។ ប្រទេសកម្ពុជាក៏ត្រូវបន្តបង្កើតច្បាប់របស់ខ្លួនស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញា (IP) ផងដែរ។